# ការធ្វើតេស្តកូវីដ-19 ក្នុងរដ្ឋកាលីហ្វូញ៉ា – អ្វីដែលអ្នកត្រូវដឹង



## ការធ្វើតេស្ត នៅផ្ទះហើយរក្សាមិត្តគ្រួសារ និងសហគមន៍អ្នកឲ្យមានសុវត្ថិភាព ។

### តើខ្ញុំគួរតែធ្វើតេស្តិរកកូវីដ-19 ពេលណា?

1. **ប្រសិនបើអ្នកមានរោគសញ្ញា ណាមួយ នៃកូវីដ-19,**
   - តេស្តិមើលមួយរំពេច មិនថាស្ថានភាពចាក់វ៉ាក់សាំងកូវីដ-19របស់អ្នកជាអ្វីឡើយ ។
   - ប្រសិនបើតេស្តិរបស់អ្នកវេជ្ជមានប៉ុន្តែអ្នកបន្តមានរោគសញ្ញា តេស្តក្នុងរយៈពេល 24-48ម្តងទៀតនៅពេលក្រោយ ។ ចំនួនទាបរបស់វីរុស នៅដំណាក់កាលដំបូងនៃការឆ្លងជួនកាលមិនអាចចាប់បានដោយការធ្វើតេស្ត ហើយតេស្តអាចនៅតែវិជ្ជមានសម្រាប់ពីរបីថ្ងៃក្រោយមក។
2. **ប្រសិនបើអ្នកបានមាន ទំនាក់ទំនងជិតស្និទ្ធ ជាមួយអ្នកណាម្នាក់ដែលមានកូវីដ-19,**
   - ធ្វើតេស្តនៅពេលគេប្រាប់អ្នកពីការឆ្លង3-5 ថ្ងៃក្រោយពីការចម្លងប្រសិនបើអ្នកមិនមានរោគសញ្ញា ។
   - តេស្តមើលភ្លាមៗប្រសិនបើរោគសញ្ញាកើតឡើង ។
3. **ពិចារណាតេស្តមើលមុននិង 3-5 ថ្ងៃក្រោយពីការជួបជុំគ្នា ព្រឹត្តិការធំមួយឬ ការធ្វដំណើរ,** ជាពិសេសប្រសិនបើអ្នកនឹងនៅក្បែរ ប្រជាជនដែលមានហានិភ័យខ្ពស់ (នីតិជនចំណាស់មានភាពសាំខ្សោយ និងមិនបានចាក់វ៉ាក់សាំង)។

### តើខ្ញុំអាចទទួលបានឧបករណ៍ធ្វើតេស្តនៅផ្ទះនៅទីកន្លែងណា?

1. ទទួលបានការធ្វើតេស្តដោយឥតគិតថ្លៃ ជាមួយនឹងការធានា រ៉ាប់រងផ្នែកវេជ្ជសាស្ត្រ នៅហាងឱសថក្នុងស្រុករបស់អ្នក (នៅ ក្នុងហាង ឬតាមអ៊ីនធឺណិត)៖
   - MediCal ឬ Medicare – យកកាតរបស់អ្នកទៅបង្អួចហាងឱសថ ។
   - ការធានារ៉ាប់រងឯកជន - ទាក់ទងក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នកសម្រាប់ការធ្វើតេស្តដោយឥតគិតថ្លៃ ឬការទូទាត់សងវិញ ។
2. ទិញពីឱសថស្ថាន តាមមូលដ្ឋានរបស់អ្នក (ក្នុងហាងឬ អនឡាញ) ។ ឧបករណ៍តេស្តនីមួយៗធម្មតាមានតម្លៃប្រហែលជា $10 ។

### តើខ្ញុំអាចធ្វើតេស្តនៅទីណាទៀត?

ស្វែងរក ទីតាំងធ្វើតេស្តតាមអនឡាញ ឬទូរស័ព្ទ (833) 422-4255 ឬ 211 ។

### ចុះប្រសិនបើតេស្តរបស់ខ្ញុំវិជ្ជមានវិញនោះ?

អ្នកមានកូវីដ-19 ។  ទាក់ទងអ្នកផ្តល់សេវាថែទាំសុខភាពម្នាក់ដើម្បីមើលថាតើអ្នកមានសិទ្ធិសម្រាប់ ការព្យាបាលកូវីដ-19 ដើម្បីការពាររោគសញ្ញាធ្ងន់ធ្ងរ ការសម្រាកនៅមន្ទីរពេទ្យ ឬមរណភាព ។ អនុវត្តតាម អនុសាសន៍ ដើម្បីការពារការរីករាលដាល នៃជម្ងឺ ទៅអ្នកដទៃ ។ រាយការណ៍ពីតេស្តវិជ្ជមានរបស់អ្នកនៅ canotify.ca.gov។

ប្រសិនបើអ្នកមានរោគសញ្ញាធ្ងន់ធ្ងរសូមទូរស័ព្ទមក 911ឬចូលទៅមន្ទីរពេទ្យនៅក្បែរអ្នក ។

### ចុះប្រសិនបើខ្ញុំមិនអាចធ្វើការបានដោយព្រោះតែកូវីដ-19 វិញនោះ?

ប្រសិនបើអ្នកមិនអាចធ្វើការបានដោយព្រោះអ្នកមានកូវីដ-19 ឬត្រូវបានចម្លង អ្នកអាច ដាក់សុំទាមទារការធានារ៉ាប់រងពិការភាព (DI) ។ ប្រសិនើបអ្នកមិនអាចធ្វើការបានពីព្រោះអ្នកកំពុងថែទាំសមាជិកគ្រួសារដែលមានកូវីដ-19អ្នកអាច ដាក់សុំទាមទារការឈប់សម្រាកសម្រាប់គ្រួសារដែលទទួលប្រាក់ឈ្នួល (PFL)។ ទាំងពីរត្រូវតែមានលិខិតអធ្យាស្រ័យពី អ្នកផ្តល់ការថែទាំសុខភាព ។

**កូវីដ-19 អាចមានរោគសញ្ញាដូចជាគុនផ្តាសាយ អាឡេស៊ី ឬគ្រុនធំក្លូដែលរួមទាំងរោគសញ្ញាដូចតទៅ ៖**

- គ្រុនឬ រងាញាក់
- ក្អក
- ការដកដង្ហើមខ្លី ឬការពិបាកដកដង្ហើម
- ការហត់
- ការឈឺសាច់ដុំឬខ្លួន
- ឈឺក្បាល
- បាត់បង់រសជាតិឬខ្លិន
- ឈឺក
- ការស្ទះឬហៀរសំបោ
- ការចង់ក្អួត ឬការក្អួត
- រាគ

ស្កេនកូដ QR ដើម្បីទស្សនាតំណអន្តរកម្មនៅក្នុងក្រដាសផ្សាយនេះ ។

CDPH California Department of PublicHealth